# គោលការណ៍ទាំង ១០ របស់អង្គការសហប្រជាជាតិ -ប័ណ្ណព័ត៌មានស្ដីពីការជួបប្រជុំដោយសន្តិវិធី

-------------------------------------------------------------

## ១. គោរព

រដ្ឋទាំងឡាយត្រូវគោរព និងធានាសិទ្ធិគ្រប់យ៉ាងរបស់បុគ្គលទាំងឡាយដែលចូលរួមក្នុងការជួបប្រជុំ

## ២. សិទ្ធិមិនអាចដកហូតបាន

បុគ្គលគ្រប់រូប មានសិទ្ធិមិនអាចដកហូតបាន ក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី

## ៣. ការរិតត្បិតមានកម្រិត

ការរិតត្បិតទៅលើការជួបប្រជុំដោយសន្តិវិធី ត្រូវគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

## ៤. កម្លាំង

មិនត្រូវប្រើប្រាស់កម្លាំងឡើយ លុះត្រាណាតែមិនអាចចៀសវាងបានដាច់ខាត ហើយប្រសិនជាប្រើប្រាស់កម្លាំង ត្រូវតែប្រើវាឲ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ

## ៥. ការជួយសម្រួល

រដ្ឋទាំងឡាយ ត្រូវជួយសម្រួលដល់ការអនុវត្តសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី

## ៦. ការសង្កេតការណ៍

បុគ្គលគ្រប់រូប មានសិទ្ធិសង្កេតការណ៍ ឃ្លាំមើល និងកត់ត្រាការជួបប្រជុំ

## ៧. ឯកជនភាព

ការប្រមូលព័ត៌មានរបស់បុគ្គល មិនត្រូវជ្រៀតជ្រែកដល់សិទ្ធិឯកជន ឬសិទ្ធិដទៃទៀតដោយគ្មានការអនុញ្ញាតឡើយ

## ៨. ព័ត៌មាន

បុគ្គលគ្រប់រូបមានសិទ្ធិ ទទួលបានព័ត៌មានទាក់ទងនឹងការជួបប្រជុំ

## ៩. ធុរកិច្ច

សហគ្រាសធុរកិច្ចទាំងឡាយ មានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សក្នុងបរិបទនៃការជួបប្រជុំ

## ១០. ទំនួលខុសត្រូវ

រដ្ឋ និងអង្គការរបស់ខ្លួន ត្រូវមានទំនួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ទាក់ទងនឹងការជួបប្រជុំ